**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ខ្ញុំបាទ **ផន ស៊ីន** ជាសមាជិកក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី។

**សូមគោរពជូន**
**ឯកឧត្តមវេជ្ជបណ្ឌិតសាស្ត្រាចារ្យ ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**កម្មវត្ថុ៖** ការបរិច្ចាគប្រាក់បៀវត្សផ្ទាល់ខ្លួនរបស់ខ្ញុំបាទ (បន្ទាប់ពីកាត់ពន្ធលើប្រាក់បៀវត្ស) ចំនួន ៤ (ប្រាំបួន) ខែ ជូន **គណៈកម្មាធិការជាតិប្រយុទ្ធនឹងជំងឺកូវីដ១៩ (COVID-19)**។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន **ឯកឧត្តមវេជ្ជបណ្ឌិតសាស្ត្រាចារ្យរដ្ឋមន្ត្រី** មេត្តាជ្រាបថា ក្នុងស្មារតីរួមចំណែកជាមួយរាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩ (COVID-19) ដែលកំពុងបន្តរាលដាល ខ្ញុំបាទសូមចូលរួមបរិច្ចាគប្រាក់បៀវត្សផ្ទាល់ខ្លួនរបស់ខ្ញុំបាទ (បន្ទាប់ពីកាត់ពន្ធលើប្រាក់បៀវត្ស) ចំនួន ៤ (ប្រាំបួន) ខែ គិតចាប់ពីខែមេសា ដល់ខែធ្នូ ឆ្នាំ២០២០ ជូន **គណៈកម្មាធិការជាតិប្រយុទ្ធនឹងជំងឺកូវីដ១៩ (COVID-19)**។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមវេជ្ជបណ្ឌិតសាស្ត្រាចារ្យរដ្ឋមន្ត្រី** មេត្តាជ្រាប និងចាត់ចែងដោយសេចក្តីអនុគ្រោះ។

សូម **ឯកឧត្តមវេជ្ជបណ្ឌិតសាស្ត្រាចារ្យរដ្ឋមន្ត្រីក្រសួងសុខាភិបាល** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃសុក្រ ១១ កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី៣ ខែមេសា ឆ្នាំ២០២០

**ហត្ថលេខា**

**ផន ស៊ីន**

**ចម្លងជូន:**

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ទីស្តីការគណៈរដ្ឋមន្ត្រី

*"ដើម្បីគោរពជូនជ្រាប"*

03/04/20